# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៥/អនក្រ.បក
### ស្ដីពីការបង្កើតគណកម្មការតាមដានដំណើរការ
### បែងចែកជំនួយសំរាប់ការងារសង្គមកិច្ច

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥/អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ
- ផ្អែកលើការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១ .-** បង្កើតគណកម្មការតាមដានដំណើរការបែងចែកជំនួយ ដែលបានមកពីប្រទេសនិងស្ថាប័នអន្តរជាតិនានា សំរាប់ការងារសង្គមកិច្ច ។

**មាត្រា ២ .-** គណកម្មការនេះ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ | ជាប្រធាន |
| ២- ឯកឧត្តម គង់ ទិមុល | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |

www.pheakdeylaw.com

៣- ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

៤- ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

៥- ឯកឧត្តម នឹម ថុន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក

៦- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៧- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក

៨- ឯកឧត្តម លី ធុច រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

៩- ឯកឧត្តម ចាន់ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

**មាត្រា ៣ ._** គណៈកម្មការខាងលើមានភារកិច្ចដូចខាងក្រោម :

- តាមដានវាយតម្លៃភាពបែងចែកជំនួយ របស់ប្រទេសនិងស្ថាប័នអន្តរជាតិ ម្ចាស់អំណោយនានា សំរាប់ការងារសង្គមកិច្ចក្នុងគោលបំណងធានាអោយបាននូវការបែងចែក អោយដល់គោលដៅ និងការប្រើប្រាស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើននូវជំនឿជាក់ពីប្រទេសផ្តល់ជំនួយ
- វិភាគអំពីសមាមាត្រនៃការបែងចែកអោយបានសមស្របតាមទំហំការងារភារកិច្ច ប្រៀបធៀបសមាមាត្រ នៃការចំណាយរវាងផ្នែកសេដ្ឋកិច្ច យោធា នគរបាល និងការចំណាយផ្នែកសង្គមកិច្ច លើផ្នែកផ្សេងៗទៀតនៃជីវភាពជាតិសំដៅអោយមានការចំណាយយ៉ាងសមស្រប ទៅលើផ្នែកសង្គមកិច្ច
- ចូលរួមប្រជុំការងារអោយបានសកម្មតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ សំដៅរកគន្លឹះប្រសិទ្ធភាពទប់ស្កាត់រាល់ភាពអសកម្ម ក្នុងការបែងចែក
- តាមដានការអភិវឌ្ឍន៍នៃការចំណាយផ្នែកសង្គមកិច្ច
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈកម្មការជូននាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលតាមកាលបរិច្ឆេទ ដែលបានកំណត់ក្នុងរបបរាយការណ៍ ។

**មាត្រា ៤ ._** គណៈកម្មការតាមដានដំណើរការបែងចែកជំនួយ សំរាប់ការងារសង្គមកិច្ច មានក្រុមការងារអន្តរក្រសួងមួយ ដែលមានសមាសភាពចូលរួមពីអ្នកបច្ចេកទេសមកពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធខាង

www.pheakdeylaw.com

លើជាជំនួយការខាងផ្នែកបច្ចេកទេសដោយធ្វើសហការយ៉ាងជិតស្និតជាមួយ គណៈកម្មការគ្រប់គ្រងវិនិយោគសាធារណៈ ដែលបានបង្កើតដោយអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ ។

មាត្រា ៥ ._ គណៈកម្មការតាមដានដំណើរការបែងចែកជំនួយ សំរាប់ការងារសង្គមកិច្ច មានលេខាធិការដ្ឋានមួយដែលមានទីតាំងនៅក្រសួងផែនការ សំរាប់ជាជំនួយការក្នុងការងាររដ្ឋបាលប្រចាំ ។

មាត្រា ៦ ._ គណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័ន ឬមន្ត្រីជំនាញ ដែលមានការពាក់ព័ន្ធមកចូលរួមប្រជុំតាមការជាក់ស្តែង ។

មាត្រា ៧ ._ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការក្នុងកិច្ចដំណើរការរបស់ខ្លួន ។

មាត្រា ៨ ._ គណៈកម្មការតាមដានដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច មានថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងផែនការ ។

មាត្រា ៩ ._ អនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការតាមដាន ដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០._ អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ១១._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធ និងលោកជំទាវ ឯកឧត្តម ដែលមាននាម ចែងក្នុងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

**ឆាយ ថន**

★★★

www.pheakdeylaw.com